## សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃសន្និសីទលើកទី ១៩
## នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

# ការបាត់បង់ និងការខូចខាត

### ដែលទាក់ទងជាមួយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ


លោក ស៊ុំ ធី

ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ

ក្រសួងបរិស្ថាន


UNEP

MINISTRY FOR FOREIGN AFFAIRS OF FINLAND

sean-cc

CAMBODIA CLIMATE CHANGE ALLIANCE

SWEDEN

# មាតិកា

1. ការបាត់បង់ និងខូចខាត ដោយសារការប្រែប្រួលអាកាសធាតុ
2. វិធីដើម្បីដោះស្រាយការបាត់បង់ និងខូចខាត
3. ប្រវត្តិនៃការបាត់បង់ និងខូចខាតនៅក្រោម UNFCCC
4. កិច្ចព្រមព្រៀងកាន់គុន - ការបាត់បង់ និងខូចខាត
5. ដំណោះស្រាយនៅដូហា - ការបាត់បង់ និងខូចខាត
6. កិច្ចប្រជុំ COP19 នៅវ៉ារស្សូវី - ការបាត់បង់ និងខូចខាត
7. ថ្នាក់ជាតិ - សកម្មភាពបន្ត

# ការបាត់បង់ និងខូចខាត ដោយសារការប្រែប្រួលអាកាសធាតុ

- ការបាត់បង់អាចជា ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដែលមិនអាចស្តារឡើងវិញបាន, ការខូចខាតគឺជាផលប៉ះពាល់ដែលអាចស្តារមកវិញបាន (Kreft et al., 2012)
- សេដ្ឋកិច្ច៖ ការបាត់បង់ និងការខូចខាត ចំពោះទ្រព្យសម្បត្តិរូបវន្ត ដែលរួមទាំងនៅក្នុងដំណើរការគណនាជាផ្លូវការផងដែរ
- មិនមែនសេដ្ឋកិច្ច៖ការបាត់បង់ដែលមិនរាប់បញ្ចូលនៅក្នុងដំណើរការគណនាជាផ្លូវការ ដូចជា ការបាត់បង់វប្បធម៌ ផលប៉ះពាល់ខាងសង្គម និងស្មារតី និងការបាត់បង់ជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី (Morissey & Oliver-Smith, 2013)

# វិធីដើម្បីដោះស្រាយការបាត់បង់ និងខូចខាត

- វិធីពីរដើម្បីដោះស្រាយការបាត់បង់ និងការខូចខាត (L&D):
  - បញ្ចៀស L&D តាមរយៈការកាត់បន្ថយ ការបន្សាំ និងកាត់បន្ថយហានិភ័យ
  - ដោះស្រាយ L&D ដែលនៅសេសសល់ តាមរយៈ៖
    - វិធានការផ្ទេរហានិភ័យ ដូចជា ការធានារ៉ាប់រង
    - ការតំកល់ទុកហានិភ័យ ដូចជា បណ្តាញសុវត្ថិភាពសង្គម និងគោលនយោបាយគាំពារសង្គម និងមូលនិធិយថាភាព
    - វិធាននានាដើម្បីដោះស្រាយL&D ពីដំណើរការចាប់ផ្តើមយឺតយ៉ាវ ដូចជា គោលនយោបាយ ដើម្បីសម្រួលដល់ការកាត់បន្ថយ និងការប្តូរទីតាំង (UNFCCC, 2012)

# ប្រវត្តិនៃការបាត់បង់ និងខូចខាតនៅក្រោម UNFCCC

- **ពីដើមទស្សវត្សរ៍ឆ្នាំ ១៩៩០ ដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ ២០០០៖** ការចរចានានានៅក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) បានផ្តោតជាចំបងលើការកាត់បន្ថយ
- **COP13-2007:** ការបាត់បង់ និងការខូចខាត បានលេចឡើងជាដំបូង ក្នុងអត្ថបទ UNFCCC នៅក្នុងផែនការសកម្មភាពបាលី ក្នុង COP13
- **COP16-2010:** កម្មវិធីការងារស្តីពីការបាត់បង់ និងការខូចខាត បានបង្កើតឡើងនៅក្នុង COP16 ដើម្បីពង្រឹងការយល់ដឹងក្នុងប្រទេសកំពុងអភិវឌ្ឍន៍
- **COP18-2012:** ការសម្រេចបង្កើតរចនាសម្ព័ន្ធស្ថាប័នស្តីពីការបាត់បង់ និងការខូចខាតនៅក្នុង COP 19 នៅទីក្រុងវ៉ាសូវី នាឆ្នាំ ២០១៣

# កិច្ចព្រមព្រៀងកាន់គុន - ការបាត់បង់ និងខូចខាត

- *ទទួលស្គាល់អំពីតម្រូវការឲ្យពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ* និងជំនាញដើម្បីស្វែងយល់ និងកាត់បន្ថយការបាត់បង់ និងការខូចខាតដែលពាក់ព័ន្ធជាមួយឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ផលប៉ះពាល់ ដែលទាក់ទងជាមួយព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី និងការចាប់ផ្តើមយឺតយ៉ាវ
- *សម្រេចបង្កើតកម្មវិធីការងារ ដែលរួមទាំងតាមរយៈសិក្ខាសាលា និងកិច្ចប្រជុំនៃអ្នកជំនាញ ទៅតាមករណីសមស្រប ដើម្បីពិចារណា* វិធាននានាដែលពាក់ព័ន្ធជាមួយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលងាយរងគ្រោះជាពិសេស ដោយសារឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ
- *ស្នើសុំអង្គភាពសម្រាប់អនុវត្តដើម្បីឯកភាពលើ* សកម្មភាពដែលត្រូវអនុវត្តនៅក្រោម កម្មវិធីការងារដែលបានកត់សំគាល់ពីខាងដើម

# ដំណោះស្រាយនៅដូហា - ការបាត់បង់ និងខូចខាត

- តួនាទីរបស់អនុសញ្ញាក្នុងការលើកកំពស់ការអនុវត្តវិធាននានា ដើម្បីដោះស្រាយការបាត់បង់ និងការខូចខាតគឺ៖
  – ពង្រឹងចំណេះដឹង និងការយល់ដឹងអំពីវិធានទូលំទូលាយសម្រាប់គ្រប់គ្រងហានិភ័យ ដើម្បីដោះស្រាយការបាត់បង់ និងការខូចខាត ដែលទាក់ទងនឹងឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ផលប៉ះពាល់នៃការចាប់ផ្តើមយ៉ាវផងដែរ
  – ពង្រឹងការពិភាក្សា ការសម្របសម្រួល សង្គតិភាព និងភាពបំពេញគ្នាក្នុងចំណោម អ្នកពាក់ព័ន្ធនានា
  – ពង្រឹងសកម្មភាព និងការគាំទ្រ ដែលរួមទាំង ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការកសាងសមត្ថភាព ដែលទាក់ទងជាមួយឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ
- ការចាត់ចែងស្ថាប័នដើម្បីដោះស្រាយការខូចាត និងការបាត់បង់ - ដូចជា យន្តការអន្តរជាតិ - នឹងត្រូវបង្កើតឡើងនៅក្នុង COP 19 ដែលត្រូវធ្វើឡើងនៅទីក្រុងវ៉ាស្សូវី នាខែវិច្ឆិកា ឆ្នាំ ២០១៣ (UNFCCC, 2013)

# កិច្ចប្រជុំ COP19 នៅវ៉ាសូវី - ការបាត់បង់ និងខូចខាត

- បានសម្រេចបង្កើត *យន្តការអន្តរជាតិវ៉ាសូវី សម្រាប់ការបាត់បង់ និងការខូចខាត នៅក្រោមក្របខ័ណ្ឌបន្សាំកាន់គុន* ដើម្បីដោះស្រាយការបាត់បង់ និងការខូចខាតដែលពាក់ព័ន្ធជាមួយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំងព្រឹត្តិការណ៍មិនប្រក្រតី និងការចាប់ផ្តើមយឺតយ៉ាវ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលងាយរងគ្រោះ
- *បង្កើតគណៈកម្មាធិការប្រតិបត្តិ*ដែលមានតំណាងពីររូបមកពីអង្គភាពនីមួយៗដូចខាងក្រោមនៅក្រោមអនុសញ្ញានេះ, ការធានាថា មានតំណាងប្រកបដោយតុល្យភាពរវាងភាគីប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍៖ គណៈកម្មាធិការបន្សាំ ក្រុមអ្នកជំនាញការស្តីពីប្រទេសអភិវឌ្ឍន៍តិចតួច គណៈកម្មាធិការអចិន្ត្រៃយ៍ខាងហិរញ្ញវត្ថុ គណៈកម្មាធិការប្រតិបត្តិខាងបច្ចេកវិទ្យា និងក្រុមអ្នកជំនាញពិគ្រោះយោបល់ខាងរបាយការណ៍ជាតិពីភាគីនានាមិននៅក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញានេះ។

# កិច្ចប្រជុំ COP19 នៅវ៉ាសូវី - ការបាត់បង់ និងខូចខាត

## *មុខងារនៃយន្តការអន្តរជាតិក្រុងវ៉ាសូវីសម្រាប់ការបាត់បង់ និងការខូចខាត* **(1/3):**

(a) ពង្រឹងចំណេះដឹង និងការយល់ដឹងអំពីវិធានទូលំទូលាយសម្រាប់គ្រប់គ្រងហានិភ័យ ដើម្បីដោះស្រាយការបាត់បង់ និងការខូចខាត ដែលទាក់ទងនឹងឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ផលប៉ះពាល់នៃការចាប់ផ្តើមយឺតយ៉ាវ ប៉ុន្តែដែលសម្រួល និងជម្រុញ៖

(i) សកម្មភាពដើម្បីដោះស្រាយភាពខ្វះខ្លោះនៃការយល់ដឹង និងជំនាញអំពីវិធាននានាសម្រាប់ដោះស្រាយការបាត់បង់ និងការខូចខាតដែលទាក់ទងជាមួយឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ផ្នែកនានាដែលមានចែងក្នុងសេចក្តីសម្រេច 3/CP.18;

(ii) ការប្រមូល ចែករំលែក គ្រប់គ្រង និងប្រើប្រាស់ទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធ ដែលរួមទាំង ទិន្នន័យដែលញែកដាច់គ្នាទៅតាមយេនឌ័រ

(iii) ការផ្តល់ជូនទិដ្ឋភាពរួមនៃទម្លាប់ល្អ ការប្រឈម បទពិសោធន៍ និងមេរៀនដែលទទួលបាន នៅក្នុងការអនុវត្តវិធាននានា ដើម្បីដោះស្រាយការបាត់បង់ និងការខូចខាត

# កិច្ចប្រជុំ COP19 នៅវ៉ាសូវី - ការបាត់បង់ និងខូចខាត

## *មុខងារនៃយន្តការអន្តរជាតិក្រុងវ៉ាសូវីសម្រាប់ការបាត់បង់ និងការខូចខាត (2/3):*

(b) ពង្រឹងការពិភាក្សា ការសម្របសម្រួល សង្គតិភាព និងភាពបំពេញគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដោយៈ

(i) ផ្តល់ការដឹកនាំ និងការសម្របសម្រួល និងការត្រួតពិនិត្យនៅក្នុងករណីសមស្រប នៅក្រោមអនុសញ្ញានេះ អំពីការវាយតម្លៃ និងការអនុវត្តវិធាននានា ដើម្បីដោះស្រាយការបាត់បង់ និងការខូចខាត ដែលទាក់ទងនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងព្រឹត្តិការណ៍ដែលចាប់ផ្តើមយឺតយ៉ាវ ជាមួយឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ

(ii) ពង្រឹងការពិភាក្សា ការសម្របសម្រួល សង្គតិភាព និងភាពបំពេញគ្នា ក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ដែលពាក់ព័ន្ធ ស្ថាប័ន អង្គភាព ដំណើរការ និង កិច្ចផ្តួចផ្តើមនានា នៅក្រៅអនុសញ្ញានេះ ក្នុងគោលដៅលើកកំពស់កិច្ចសហប្រតិបត្តិការ និងកិច្ចសហការនៅទូទាំងការងារ និងសកម្មភាពដែលពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់។

• 2

# កិច្ចប្រជុំ COP19 នៅវ៉ាសូវី - ការបាត់បង់ និងខូចខាត

## *មុខងារនៃយន្តការអន្តរជាតិក្រុងវ៉ាសូវីសម្រាប់ការបាត់បង់ និងការខូចខាត (3/3):*

(c) ពង្រឹងសកម្មភាពនិងការគាំទ្រ ដែលរួមទាំង ហិរញ្ញវត្ថុ បច្ចេកវិទ្យា ការកសាងសមត្ថភាព ដើម្បីដោះស្រាយការបាត់បង់និងការខូចខាត ដែលទាក់ទងជាមួយឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដើម្បីជួយប្រទេសនានាអនុវត្តសកម្មភាពនានា អនុលោមតាមសេចក្តីសម្រេច 3/CP.18, វាក្យខ័ណ្ឌ ៦ ដែលរួមទាំង តាមរយៈ៖

(i) ផ្តល់ការគាំទ្រ និងការណែនាំអំពីវិធាននានា ដើម្បីដោះស្រាយការបាត់បង់ និងការខូចខាត ដែលពាក់ព័ន្ធនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី និងការចាប់ផ្តើមយឺតយ៉ាវផងដែរ

(ii) ការផ្តល់ព័ត៌មាន និងអនុសាសន៍នានាសម្រាប់ពិចារណានៅក្នុងសន្និសីទភាគី នៅពេលផ្តល់ការណែនាំដែលពាក់ព័ន្ធ ដើម្បីកាត់បន្ថយហានិភ័យនៃការបាត់បង់ និងការខូចខាត និងនៅក្នុងករណីចាំបាច់ ដោះស្រាយការបាត់បង់ និងការខូចខាត ដែលរួមទាំង អង្គភាពអនុវត្តនៃយន្តការហិរញ្ញវត្ថុនៅក្រោមអនុសញ្ញានេះផងដែរ ទៅតាមករណីសមស្រប

(iii) សម្រួលដល់ការកៀងគរ និងការស្វែងអ្នកជំនាញ និងពង្រឹងការគាំទ្រ ដែលរួមទាំង ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការកសាងសមត្ថភាព ដើម្បីពង្រឹងវិធាននានាដែលមានស្រាប់ និងក្នុងករណីចាំបាច់ សម្រួលឲ្យមានការបង្កើត និងអនុវត្តវិធាននានាជាបន្ថែម ដើម្បីដោះស្រាយការបាត់បង់ និងការខូចខាត ដែលទាក់ទងជាមួយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី និងការដែលចាប់ផ្តើមយឺតយ៉ាវផងដែរ

# កិច្ចប្រជុំ COP19 នៅវ៉ាសូវី - ការបាត់បង់ និងខូចខាត

- *ស្នើសុំទៅគណៈកម្មាធិការប្រតិបត្តិ ឲ្យបង្កើតផែនការការងារដំបូងរបស់ខ្លួនសម្រាប់រយៈពេល២ឆ្នាំ* សម្រាប់អនុវត្តមុខងារនានា ដែលរួមទាំង កាលវិភាគសម្រាប់ការប្រជុំ ដោយគិតផងដែរអំពីបញ្ហានានាដែលមានចែងនៅក្នុងសេចក្តីសម្រេច 3/CP.18 សម្រាប់ការពិចារណានៅក្នុងសម័យប្រជុំលើកទី៤១ នៃអង្គភាពផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពទទួលបន្ទុកកិច្ចការអនុវត្ត (ខែធ្នូ ឆ្នាំ ២០១៤)
- *អញ្ជើញភាគីនានាឲ្យធ្វើការតាមរយៈអ.ស.ប និងស្ថាប័នពាក់ព័ន្ធដទៃទៀត* ទីភ្នាក់ងារឯកទេស និងដំណើរការនានា ទៅតាមករណីសមស្រប ដើម្បីលើកកំពស់សង្គតិភាពនៅគ្រប់លំដាប់ថ្នាក់ អំពីវិធាននានាដែលពាក់ព័ន្ធ សម្រាប់ដោះស្រាយការបាត់បង់ និងការខូចខាត ដែលពាក់ព័ន្ធជាមួយឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ព្រឹត្តិការណ៍មិនប្រក្រតី និងការចាប់ផ្តើមយឺតយ៉ាវផងដែរ

# កិច្ចប្រជុំ COP19 នៅវ៉ាសូវី - ការបាត់បង់ និងខូចខាត

- *អញ្ជើញភាគីនានា* ដើម្បីពង្រឹង និងនៅក្នុងករណីសមស្រប បង្កើតស្ថាប័ន និងបណ្តាញនានា នៅថ្នាក់តំបន់ និងថ្នាក់ជាតិ ជាពិសេស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលងាយរងគ្រោះ ដើម្បីពង្រឹងការអនុវត្តវិធាននានាដែលពាក់ព័ន្ធសម្រាប់ដោះស្រាយការបាត់បង់ និងការខូចខាត តាមវិធីដែលមានប្រទេសម្ចាស់ផ្ទះជាអ្នកនាំមុខ, លើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធនានា, និងកែលម្អលំហូរព័ត៌មាន
- *ស្នើភាគីប្រទេសជឿនលឿន* ឲ្យផ្តល់ទៅភាគីប្រទេសកំពុងអភិវឌ្ឍន៍នូវហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការកសាងសមត្ថភាព អនុលោមតាមសេចក្តីសម្រេច1/CP.16 និងសេចក្តីសម្រេចពាក់ព័ន្ធដទៃទៀតនៃសន្និសីទភាគី។
- *សម្រេច*ធ្វើការពិនិត្យយន្តការអន្តរជាតិវ៉ាសូវី ដែលរួមទាំង រចនាសម្ព័ន្ធ អាណត្តិ និង ប្រសិទ្ធិភាពរបស់ខ្លួននៅក្នុង COP-22 ក្នុងគោលដៅអនុម័តសេចក្តីសម្រេចសមស្រប លើលទ្ធផលនៃការពិនិត្យនេះ។

# ថ្នាក់ជាតិ - សកម្មភាពបន្ត

- ពង្រឹង និងបង្កើតស្ថាប័ន និងបណ្តាញនានានៅថ្នាក់តំបន់ និងថ្នាក់ជាតិ ដើម្បីពង្រឹងការអនុវត្តវិធានពាក់ព័ន្ធនានា សម្រាប់ដោះស្រាយការបាត់បង់ និងការខូចខាត តាមគំរូដែលប្រទេសម្ចាស់ផ្ទះជាអ្នកនាំមុខ
- ផ្តល់ធាតុចូលសម្រាប់ផែនការការងាររយៈពេលពីរឆ្នាំដំបូង សម្រាប់អនុវត្តមុខងារនានានៃយន្តការអន្តរជាតិក្រុងវ៉ារស្សូវី សម្រាប់ដោះស្រាយការបាត់បង់ និងការខូចខាត
- ពង្រឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធនានា និងកែលម្អលំហូរព័ត៌មាន
- ចូលរួម និងពិនិត្យយន្តការអន្តរជាតិក្រុងវ៉ារស្សូវី៖ រចនាសម្ព័ន្ធ អាណត្តិ និងប្រសិទ្ធភាពសម្រាប់ COP-22

# សូមអរគុណ !

Climate Change Department, Ministry of Environment

#48 Samdech Preah Sihanouk Blvd

Phnom Penh, Cambodia

www.camclimate.org.kh